**សេចក្តីប្រកាសព័ត៌មាន**

**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**

**ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០១៩**

# កម្មវិធីជំនួយផ្ទាល់របស់ស្ថានទូតអូស្ត្រាលីបើកទទួលពាក្យស្នើសុំ

កម្មវិធីជំនួយផ្ទាល់របស់អូស្ត្រាលី (DAP) បើកទទួលពាក្យស្នើសុំសម្រាប់ឆ្នាំ២០១៩។

អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នក្នុងស្រុកនិងអន្តរជាតិអាចដាក់ពាក្យស្នើសុំថវិកាជំនួយដែលមានទឹកប្រាក់រហូតដល់ ២៥.០០០ដុល្លារអូស្ត្រាលី និងថវិកាជំនួយខ្នាតតូចមានទឹកប្រាក់រហូតដល់ ១០.០០០ដុល្លារអូស្ត្រាលី សម្រាប់គម្រោងនីមួយៗ ដើម្បីអនុវត្តគម្រោងកម្មវិធីអភិវឌ្ឍន៍ខ្នាតតូច ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងទទួលបាននូវការអភិវឌ្ឍប្រកបដោយនិរន្តភាព។ ស្ថាប័នឯកជន ក៏អាចដាក់ពាក្យស្នើសុំបានដែរ ប៉ុន្តែត្រូវអនុវត្តគម្រោងដែលទទួលមូលនិធិពីកម្មវិធីជំនួយផ្ទាល់ (DAP) ដោយមិនយកប្រាក់កម្រៃ។

ក្នុងឆ្នាំ២០១៩ កម្មវិធីជំនួយផ្ទាល់នេះនឹងផ្តល់អាទិភាពលើផ្នែកដូចខាងក្រោម៖

- សិទ្ធិមនុស្ស រួមទាំងសមភាពយេនឌ័រ និងឱកាសសំរាប់សហគមន៍ជនជាតិភាគតិច
- ការលើកកម្ពស់គម្រោងធុរកិច្ចប្រកបដោយបរិយាប័ន្នដើម្បីផលប្រយោជន៍សង្គម
- ការគ្រប់គ្រងបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តភាព
- ការអភិវឌ្ឍសមត្ថភាពផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

ឯកអគ្គរាជទូតអូស្ត្រាលី លោកជំទាវ អេនជេលឡា ខកខីរ៉េន មានប្រសាសន៍ថា៖ «ប្រទេសអូស្ត្រាលីមានភាពរីករាយបន្តគាំទ្រដល់ការអភិវឌ្ឍនៅកម្ពុជាតាមរយៈកម្មវិធីជំនួយផ្ទាល់នេះ»។

លោកជំទាវបានបន្តទៀតថា៖ «មូលនិធិនេះ នឹងជួយគាំទ្រគម្រោងអភិវឌ្ឍន៍នានា ដើម្បីជួយកម្ពុជាឲ្យកាន់តែមានភាពរឹងមាំ និងនាំមកនូវស្ថេរភាព និងភាពរីកចម្រើនក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិករបស់យើង»។

កម្មវិធីជំនួយផ្ទាល់ គឺជាកម្មវិធីមូលនិធិខ្នាតតូចដែលមានការប្រកួតប្រជែង។ ពាក្យស្នើសុំត្រូវតែឆ្លើយតបទៅនឹងតម្រូវការលំអិតនៅក្នុងគោលការណ៍ណែនាំរបស់កម្មវិធីជំនួយផ្ទាល់ ដែលមាននៅលើវេបសាយរបស់ស្ថានទូត៖ https://cambodia.embassy.gov.au/penh/cooperation.html

កាលបរិច្ឆេទឈប់ទទួលពាក្យស្នើសុំសង្ខេប (Expressions of Interests) គឺថ្ងៃទី០៣ តុលា ២០១៩ ។ ប្រសិនបើអ្នកមានសំណួរផ្សេងៗ អំពីដំណើរការនៃការដាក់ពាក្យ សូមទំនាក់ទំនងមកកាន់អ៊ីម៉ែល៖ dap.phnompenh@dfat.gov.au

ព័ត៌មានផ្សេងៗសូមទំនាក់ទំនងមកកាន់៖ Australian.Embassy.Cambodia@dfat.gov.au